# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ២០១៣

## ជប៉ុនផ្តល់៤១៥,៣៣៩ដុល្លារអាមេរិកសម្រាប់គម្រោងអភិវឌ្ឍន៍ចំនួន៤



រដ្ឋាភិបាលជប៉ុន ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) បានផ្តល់ទឹកប្រាក់សរុបចំនួន៤១៥,៣៣៩ដុល្លារអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន៤។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយទាំង៤សម្រាប់គម្រោងដូចតទៅ៖

១. គម្រោងសាងសង់មជ្ឈមណ្ឌលបណ្តុះ និងចែកចាយពូជដំឡូងមីខេត្តបាត់ដំបង (១១៨,៩៩៦ដុល្លារអាមេរិក)
ស្ថាប័នទទួលជំនួយ៖ សាកលវិទ្យាល័យបាត់ដំបង


គម្រោងមជ្ឈមណ្ឌលបណ្តុះដំឡូងមី

គម្រោងនេះគឺដើម្បីបំពាក់ធុងចំហុយសម្លាប់មេរោគពីរដែលមានទំហំ៥០ និង១៥០លីត្រ តុធ្វើការអនាម័យមួយ និងសាងសង់មន្ទីរពិសោធន៍ផ្ទះបៃតងចំនួនពីរដែលមានទំហំ ៣០០ ម៉ែត្រក្រឡា និង៦០០ ម៉ែត្រក្រឡា នៅក្នុងកសិដ្ឋានរបស់សាកលវិទ្យាល័យបាត់ដំបងដើម្បីបណ្តុះពូជដំឡូងមីដែលគ្មានមេរោគ។ គម្រោងនេះនឹងកែលម្អផលិតភាពនៃការដាំដុះដំឡូងមីរបស់ប្រជាកសិករប្រមាណ ១,១៥០ នាក់ ក្នុងសហគមន៍ជនបទក៏ដូចជាបង្កើនប្រាក់ចំណូលរបស់ពួកគេផងដែរ។ សាកលវិទ្យាល័យបាត់ដំបងក៏មានគម្រោងរៀបចំសិក្ខាសាលា និងចែកចាយពូជដំឡូងមីដែលគ្មានមេរោគដល់កសិករនៅក្នុងតំបន់ និងមន្ទីរកសិកម្មខេត្តបាត់ដំបងផងដែរ។

២. គម្រោងអភិវឌ្ឍន៍ជនបទក្នុងស្រុកសំបូរ ខេត្តក្រចេះ (៩១,១២១ដុល្លារអាមេរិក)
ស្ថាប័នទទួលជំនួយ៖ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (ស៊ី.អ.ឌី.ធី)


កសិករក្នុងតំបន់នឹងទទួលបានការបណ្តុះបណ្តាលផ្នែកកសិកម្ម

គម្រោងនេះគឺដើម្បី(១)សាងសង់ប្រព័ន្ធបន្សុទ្ធទឹកខ្នាតតូច និងដាក់បណ្តាញបំពង់ចែកចាយទឹកចំនួន៣,០០០ម៉ែត្រក្នុងភូមិកោះផ្តៅ(២)សាងសង់ប្រព័ន្ធចែកចាយទឹកសម្រាប់ធ្វើកសិកម្មដែលរួមមានអាងស្តុកទឹកចំណុះ៥,០០០លីត្រចំនួនពីរ និងប្រឡាយប្រវែង១,២០០ម៉ែត្រក្នុងភូមិសំភិន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។ ជាងនេះទៅទៀត ការបណ្តុះបណ្តាលផ្នែកកសិកម្មក៏នឹងត្រូវបានផ្តល់ជូនកសិករដែលរស់នៅក្នុងភូមិចំនួន៧នៃឃុំកំពង់ចាមផងដែរ។ ជាមួយនឹងគម្រោងនេះ កសិករ និង ប្រជាជនក្នុងតំបន់ជាង ២,០០០ នាក់នឹងអាចទទួលទានទឹកស្អាតមានសុវត្ថិភាព ក៏ដូចជាប្រើប្រាស់ទឹកពីទន្លេមេគង្គដើម្បីធ្វើកសិកម្ម និងបង្កើនផលិតភាពផងដែរ។ គម្រោងនេះក៏នឹងអនុញ្ញាតិឲ្យប្រជាជនដែលរស់នៅតំបន់អភិរក្សសត្វផ្សោតទន្លេមេគង្គប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិតជាជាងរបរនេសាទដែលអាចប៉ះពាល់ដល់សត្វផ្សោតទន្លេ។

៣. គម្រោងកែលម្អប្រព័ន្ធលូរំដោះទឹកក្នុងសង្កាត់អូរតាវៅ ខេត្តប៉ៃលិន (៩៩,៨០០ដុល្លាអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន


ផ្លូវកសិកម្ម

គម្រោងនេះគឺដើម្បីសាងសង់លូ១៤កន្លែងនិងផ្លូវបង្ហៀរទឹក៣កន្លែងតាមបណ្តោយផ្លូវកសិកម្មក្នុងសង្កាត់អូរតាវៅ ខេត្តប៉ៃលិន។ ផ្លូវនេះតភ្ជាប់ផ្លូវជាតិលេខ៥៧ទៅកាន់រមណីយដ្ឋានទឹកជ្រោះភ្នំខៀវដែលមានភ្ញៀវទេសចរណ៍មកកម្សាន្តប្រមាណប្រាំមួយម៉ឺននាក់ជារៀងរាល់ឆ្នាំ។ ជាមួយនឹងការអនុវត្តគម្រោងនេះ ប្រជាជនជាង៣,០០០នាក់ដែលរស់នៅក្នុងភូមិចំនួន៥ដែលនៅក្បែរនោះនឹងអាចធ្វើដំណើរទៅកាន់សាលាឃុំ មន្ទីរពេទ្យបង្អែក និងសាលាបឋមសិក្សាកាន់តែងាយស្រួលជាងមុន។ យើងក៏សង្ឃឹមផងដែរថា គម្រោងនេះនឹងជួយលើកស្ទួយសេដ្ឋកិច្ចនៅក្នុងតំបន់តាមរយៈការជំរុញវិស័យពាណិជ្ជកម្ម។

៣. គម្រោងកែលម្អប្រព័ន្ធលូរំដោះទឹកក្នុងក្រុង ខេត្តព្រះវិហារ (១០៥,៤២២ដុល្លាអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារ


ប្រព័ន្ធលូក្នុងក្រុងព្រះវិហារបច្ចុប្បន្ន

គម្រោងនេះគឺដើម្បីកែលម្អប្រព័ន្ធលូរំដោះទឹកប្រវែង៩០០ម៉ែត្រដែលមានប្រអប់លូ៣៦ក្នុងសង្កាត់កំពង់ប្រណាក ទីរួមខេត្តព្រះវិហារ។ ជាមួយនឹងគម្រោងនេះ ប្រជាជនប្រមាណ១០,០០០នាក់នឹងបានទទួលបានអត្ថប្រយោជន៍ពីបរិស្ថានស្អាត និងមានសុវត្ថិភាព ព្រមទាំងអាចធ្វើដំណើរកាន់តែងាយស្រួលទៅកាន់ទីតាំងសំខាន់ៗ ដូចជាមន្ទីរពេទ្យបង្អែកខេត្ត សាលាខេត្ត និងផ្សារជាដើម ដែលស្ថិតនៅតាមបណ្តោយប្រព័ន្ធលូនេះ។

ជំនួយ *គូសាណូណេ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៩.៥លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៩៥ គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*